ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ.៤៧៣............/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ១០ ឆ្នាំ២០១១.

**គោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជា**
**ប្រធានគ.ជ.អ.ប**

**កម្មវត្ថុ**; របាយការណ៍លទ្ធផលសិក្ខាសាលាអាស៊ីប៉ាស៊ីហ្វិកនៅទីក្រុងបាំងកក ស្តីពីក្របខណ្ឌហិរញ្ញប្បទាន សម្រាប់ការបំរែបំរួលអាកាសធាតុ។

តបតាមការអញ្ជើញរបស់ការិយាល័យកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំនៅទីក្រុងបាំងកក ក្រសួងមហាផ្ទៃបានចាត់តាំងរូបខ្ញុំបាទដឹកនាំគណៈប្រតិភូទៅចូលរួមសិក្ខាសាលាតំបន់អាស៊ីប៉ាស៊ីហ្វិករយៈពេលពីរថ្ងៃ ពីថ្ងៃ ១២ ដល់ ទី១៣ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីក្របខណ្ឌហិរញ្ញប្បទានសម្រាប់ការបំរែបំរួលអាកាសធាតុ នៅទីក្រុងបាំងកក ។

**សមាសភាពចូលរួម៖**

- សមាជិកចូលរួមសរុបចំនួន ១៥២រូប មកពី២៣ ប្រទេស
- ដៃគូអភិវឌ្ឍន៍ចំនួន១០ប្រទេស និងស្ថាប័ន
- គ្រួសារអង្គការសហប្រជាជាតិ ចំនួន៥ស្ថាប័ន
- សង្គមស៊ីវិលចំនួន ៣អង្គការ

**ដំណើរការសិក្ខាសាលា៖**

សិក្ខាសាលាបានដំណើរការតាមរបៀបវារៈដូចដែលបានគ្រោងទុក ហើយបានពិភាក្សាយ៉ាងផុសផុលលើប្រធានបទចំនួនប្រាំពីរ ដូចខាងក្រោម៖

១. ក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុ; ដោយធ្វើអោយប្រសើរឡើងនូវប្រសិទ្ធភាពនៃហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុកំរិតប្រទេស។ នេះជាប្រធានបទសំខាន់ដែលតម្រូវអោយមានក្រុមដឹកនាំការពិភាក្សា និងធ្វើបទអន្តរាគមន៍បង្ហាញពីបទពិសោធន៍របស់ប្រទេស និងរបស់ភាគីនអង្គការអន្តរជាតិ។

ជាមួយគ្នានេះផងដែរ រូបខ្ញុំត្រូវបានអង្គសិក្ខាសាលាអន្តរជាតិនេះជ្រើសតាំងអោយធ្វើជាប្រធាននៃក្រុមដឹកនាំការពិភាក្សាលើចំណុចសំខាន់ពីរនៅក្នុងប្រធានបទទី១ ដែលគាំទ្រដល់សកម្មភាពនៃការប្រែប្រួលអាកាសធាតុ៖

- ក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុនៅថ្នាក់មូលដ្ឋាន ដែលធ្វើការបង្ហាញដោយតំណាងគ្រួសារអង្គការសហប្រជាជាតិ
- ឧបករណ៍ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុតាមរយៈបទពិសោធន៍ពីប្រទេសប៉ូតាន់។

២. រៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុ

នៅក្នុងប្រធានបទនេះអង្គសិក្ខាសាលាបានពិភាក្សាពីទំនាក់ទំនង និងភាពជាដៃគូ រវាងរដ្ឋ និងវិស័យឯកជនក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុ។

៣. គណៈប្រតិភូប្រទេសនីមួយៗ ធ្វើការពិភាក្សាដើម្បីរៀបចំ ក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុ

ប្រធានបទនេះតម្រូវអោយប្រទេសនីមួយៗ ដែលបានចូលរួមនៅក្នុងសិក្ខាសាលានេះ ធ្វើការពិភាក្សា និងរៀបចំក្របខ័ណ្ឌការងារទៅអនាគតដើម្បីគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុ និងកំណត់ពីជំហានបន្ទាប់ និងតម្រូវការគាំទ្រ។ គណៈប្រតិភូកម្ពុជាបានពិភាក្សានឹងដាក់ចេញនូវយុទ្ធសាស្ត្រដូចខាងក្រោម៖

អនុសាសន៍សម្រាប់ប្រទេសកម្ពុជា

១.កត់ត្រានិងតាមដាន នៃហិរញ្ញប្បទាន បំរែបំរួលអាកាសធាតុ

២.ការចំណាយសម្រាប់វិនិយោគការប្រែប្រួលអាកាសធាតុត្រូវផ្អែកលើផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ

៣.បង្កើតយន្តការត្រួតពិនិត្យគួរឱ្យទុកចិត្តបាន ដែលពាក់ព័ន្ធដូចខាងក្រោម ៖

- ក្របខ័ណ្ឌការងារនៃការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃឱ្យបានម៉ត់ចត់
- ឯករាជ្យភាពក្នុងការធ្វើសវនកម្មហិរញ្ញវត្ថុ និងវាយតម្លៃការអនុវត្តការងារ
- មានការចូលរួម និងការផ្តល់យោបល់ត្រលប់ពីក្រុមអ្នកទទួលផល

អនុសាសន៍សម្រាប់សហគមន៍អន្តរជាតិ

១.កំណត់ឈ្មោះហិរញ្ញប្បទាននៃបំរែបំរួលអាកាសធាតុអោយបានច្បាស់លាស់

២.គាំទ្រដល់ការរៀបចំនូវលំហូរបាយការណ៍ស្តីពីបំរែបំរួលអាកាសធាតុ

៣.សម្របសម្រួលលើយន្តការអន្តរាគមន៍ជាយុទ្ធសាស្ត្រតាមវិស័យផ្សេងៗដែលនាំឱ្យប្រទេសនិមួយៗបានត្រៀមខ្លួនរួចជាស្រេច ក្នុងការគ្រប់គ្រងមូលនិធិបំរែបំរួលអាកាសធាតុ

ជំហានបន្ទាប់របស់ប្រទេសកម្ពុជា

១.បញ្ចប់ផែនការយុទ្ធសាស្ត្របំរែបំរួលអាកាសធាតុរបស់ប្រទេសកម្ពុជា

២. វិភាគសម្រាប់គំរូមូលនិធិរួម (Trust Fund) និងកំណត់សេចក្តីត្រូវការដើម្បីបង្កើត និង គ្រប់គ្រងមូលនិធិរួម (Trust Fund)

៣.រៀបចំផែនទីបង្ហាញផ្លូវថ្នាក់ជាតិសម្រាប់មូលនិធិរួមបំរែបំរួលអកាសធាតុថ្នាក់ជាតិ

៤.ពង្រឹងសមត្ថភាពរបស់គណកម្មាធិការជាតិគ្រប់គ្រងបំរែបំរួលអកាសធាតុនិងក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីសម្របសម្រួលនិងផ្តល់ការត្រួតពិនិត្យ

៥.គាំទ្រដល់ការរៀបចំផែនទីបង្ហាញផ្លូវបំរែបំរួលអាកាសធាតុតាមវិស័យនីមួយៗ។

៤. រៀបចំដៃគូពិភាក្សារវាងប្រទេស និងប្រទេស

បន្ទាប់ពីបានធ្វើបទបង្ហាញ និងពិភាក្សារួមរួចមក អង្គសិក្ខាសាលាបានបំបែកជាក្រុមតូចៗចាប់ដៃគូប្រទេស និងប្រទេស។ កម្ពុជាបានចាប់ដៃគូពិភាក្សាជាមួយប្រទេសបង់ក្លាដែស និងបានចែករំលែកបទពិសោធន៍ក្របខ័ណ្ឌហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុ និងបានកណត់ពីអនុសាសន៍រួមសម្រាប់ប្រទេស តំបន់ និងអ្នកពាក់ព័ន្ធអន្តរជាតិ ដើម្បីធ្វើអោយប្រសើឡើងនូវប្រសិទ្ធភាពនៃហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុ។

៥.តើដំណើរការគោលនយោបាយអន្តរជាតិដែលទាក់ទងនឹងមូលនិធិបំរែបំរួលអាកាសធាតុនិងការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព?

៦.ពិភាក្សានិងពិនិត្យមើលនូវវិធានការណ៍បន្ទាប់ដោយប្រទេសនិមួយៗក្នុងគោលបំណងធ្វើអោយប្រសើឡើងក្របខ័ណ្ឌការងារបំរែបំរួលអាកាសធាតុ

៧.អនុសាសន៍ដើម្បីធ្វើអោយប្រសើឡើងនូវប្រសិទ្ធភាពរបស់មូលនិធិការបំរែបំរួលអាកាសធាតុតាមរយៈកិច្ចសហប្រតិបត្តិការរបស់ប្រទេសនិមួយៗ ថ្នាក់តំបន់ និងជាកំរិតអន្តរជាតិ

តាមរយៈការពិភាក្សាបានកំណត់នូវសមិទ្ធផលជាគន្លឹះចំនួនបីនៅក្នុងក្របលក្ខខ័ណ្ឌការងារដែលនឹងជួយដល់ថ្នាក់ដឹកនាំប្រទេសក្នុងការគ្រប់គ្រងហិរញ្ញប្បទាន សម្រាប់ការបំរែបំរួលអាកាសធាតុប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្របខណ្ឌការងារតម្រូវអោយមានការប្រែប្រួលទៅតាមបរិបទរបស់ប្រទេសនីមួយៗនិងសង្ខេបនូវសមិទ្ធផលចំនួនបីសំខាន់ៗដូចខាងក្រោម ៖

- គោលនយោបាយនិងវិធានការណ៍បំរែបំរួលអាកាសធាតុមានតំលៃនិងជាអាទិភាព ហើយនិងឆ្លុះបញ្ចាំងទៅនឹងដំណើរការការកសាងផែនការនិងថវិកា នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

- ការចំណាយដែលទាក់ទងទៅនឹងការបំរែបំរួលអាកាសធាតុត្រូវបានគ្រប់គ្រង និង អនុវត្តទៅតាមប្រព័ន្ធរបស់ប្រទេសនិមួយៗនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងកម្មវិធី និងលទ្ធកម្ម
- ក្របខ័ណ្ឌនៃការទទួលខុសគឺត្រូវការរៀបចំរបាយការណ៍ចំណាយដែលទាក់ទងនឹង ការបំរែបំរួលអាកាសធាតុនិងចំណាយប្រតិបត្តិការផ្សេងៗទៀត។

<u>គំនិតផ្តួចផ្តើមសំខាន់ៗដែលនឹងត្រូវលើកឡើងជាអនុសាសន៍នៅកិច្ចប្រជុំកំពូល ស្តីពីប្រសិទ្ធភាពជំនួយ នៅបូសាន សាធារណៈរដ្ឋកូរ៉េ</u>

ដើម្បីសម្រេចអោយបាននូវសមិទ្ធផលទាំងនេះ ប្រទេសកំពុងអភិវឌ្ឍន៍ និង ដៃគូអភិវឌ្ឍន៍ បានកំណត់គំនិតផ្តួចផ្តើមសំខាន់ៗ ដើម្បីគាំទ្រអោយគ្នាទៅវិញទៅ មកធ្វើអោយការអនុវត្តនៅក្នុងប្រទេស តំបន់ និងអន្តរជាតិប្រកបដោយនិរន្តរភាព និងមិនត្រូវបន្ថែមចំណាយប្រតិបត្តិការ។ ផ្ទុយទៅវិញ គំនិតផ្តួចផ្តើមសំខាន់ៗនឹង ជួយអោយមានភាពងាយស្រួលក្នុងការប្រមូលផ្តុំនូវសកម្មភាពលើហិរញ្ញប្បទាន បំរែបំរួលអាកាសធាតុដែលដឹកនាំដោយប្រទេសនិមួយៗនិងកាត់បន្ថយគំលាត ដែលបានកំណត់សម្រាប់ការតាមដាននិងវាយតំលៃ ឧទាហរណ៍ការអនុវត្តលើ កិច្ចព្រមព្រៀងទីក្រុងម៉ុងតេរី ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍន៍ និងសេចក្តីប្រកាស ស្តីពីជំនួយទីក្រុងប៉ារីស។

ចុងបញ្ចប់សិក្ខាសាលាបានឯកភាពគ្នាដាក់ចេញនូវសកម្មភាពដែលនឹង អនុវត្តក្នុងចំណោមសកម្មភាព ផ្សេងទៀត រួមមាន

<u>មួយ: គោលនយោបាយ និងវិធានការណ៍បំរែបំរួលអាកាសធាតុមានតំលៃ និងជា អាទិភាព ហើយត្រូវឆ្លុះបញ្ចាំងនៅក្នុងដំណើរការការកសាងផែនការ និងថវិកានៅ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ</u>

ការលើកទឹកចិត្តអោយប្រទេសកំពុងអភិវឌ្ឍន៍ ៖

- កំណត់នូវសូចនាករអោយបានច្បាស់នៅក្នុងផែនការថ្នាក់ជាតិ ផែនការ តាមវិស័យ និងផែនការថ្នាក់ក្រោមជាតិ។
- កំណត់នូវអ្វីដែលជាចំណាយបន្ទាន់ និងចំណាយរយៈវែងលើបំរែបំរួល អាកាសធាតុនៅថ្នាក់ជាតិ និងរដ្ឋបាលក្រោមជាតិ តាមវិស័យផ្សេងៗ អនុវិស័យ កម្មវិធី និងសកម្មភាពផ្សេងៗ។
- កំណត់រៀបចំ និងប្រើប្រាស់តាមជំពូកថវិកាជាក់លាក់ និងតាមខ្ទង់ថវិកា

ជូននៃបទពិសោធន៍ល្អជាអន្តរជាតិ និងជួយសរុបរាល់ចំណាយរបស់គ្រប់ថ្នាក់រដ្ឋបាល និងគ្រប់វិស័យ។

- ការចំណាយទៅលើបំរែបំរួលអាកាសធាតុដោយដំណើរការតាមប្រព័ន្ធដែលមានស្រាប់នៃការចំណាយសាធារណៈជាអាទិភាពដោយគិតពិចារណាទៅលើការវាយតំលៃនិងទិន្នន័យមូលដ្ឋានទាក់ទងទៅនឹងការបំរែបំរួលអាកាសធាតុដែលអាចប្រើប្រាស់បាន។
- ផ្តល់ឱកាសអោយភ្នាក់ងារឯកជនធ្វើជាដៃគូជាមួយរដ្ឋាភិបាលនិងភ្នាក់ងារពាក់ព័ន្ធថ្នាក់ជាតិផ្សេងទៀតដោយរួមបញ្ចូលទាំងសង្គមស៊ីវិលចំពោះការវិនិយោគទុនត្រូវអនុវត្តអោយបានម៉ត់ចត់នូវផលប៉ះពាល់សុវត្ថិភាពសង្គម បរិស្ថាន និងសកម្មភាពនៃការទទួលខុសត្រូវរបស់សង្គមទាំងមូល
- គាំទ្រដល់រដ្ឋាភិបាលថ្នាក់ក្រោមជាតិដើម្បីពង្រឹងតួនាទីរបស់ថ្នាក់រដ្ឋបាលនេះចំពោះការចំណាយ និងការកំណត់អាទិភាពលើការបំរែបំរួលអាកាសធាតុទៅក្នុងផែនការ និងថវិកា ដោយត្រូវឆ្លុះបញ្ចាំងអំពីពីផលប៉ះពាល់នៃការបំរែបំរួលអាកាសធាតុជាពិសេសចំពោះភាពប្រឈមនៅថ្នាក់មូលដ្ឋាន។

<u>ការលើកទឹកចិត្តដល់ដៃគូអភិវឌ្ឍន៍</u>

- ស្របជាមួយកិច្ចព្រមព្រៀងអន្តរជាតិ និងជាតិដែលបានអនុម័ត ត្រូវធានាថាមូលនិធិបំរែបំរួលអាកាសធាតុត្រូវប្រើប្រាស់ប្រកបដោយតម្លាភាពរួមបញ្ចូលទាំងការប៉ាន់ស្មាននូវប្រភពហិរញ្ញវត្ថុបន្ថែម និងប្រភពថ្មី ដែលងាយស្រួលទទួលយកនិងរៀបចំបែបបទដើម្បីគាំទ្រដល់ការសំរេចចិត្តរបស់ប្រទេសនិមួយៗដែលផ្អែកតាមព័ត៌មានរបស់ប្រភពមូលនិធិទាំងអស់ដែលមាន។
- ពង្រឹងការធ្វើផែនការនិងថវិកានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិតាមរយៈការផ្តល់ព័ត៌មានលម្អិតជាទៀងទាត់ និងទាន់ពេលវេលាស្របតាមផែនការរបស់ប្រទេសនីមួយៗ។
- ចែករំលែកនិងគាំទ្រដល់ការកំណត់ចំណាយលើបំរែបំរួលអាកាសធាតុដោយរួមទាំងភាពបន្សាំ និងដំណោះស្រាយ។

<u>ពីរៈ</u> <u>ការចំណាយដែលទាក់ទងទៅនឹងបំរែបំរួលអាកាសធាតុត្រូវបានគ្រប់គ្រងនិងអនុវត្តតាមប្រព័ន្ធរបស់ប្រទេសនិមួយៗ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ</u>

ការលើកទឹកចិត្តអោយប្រទេសកំពុងអភិវឌ្ឍន៍ ៖

- ធ្វើការវាយតំលៃលើការខិតខំប្រឹងប្រែងក្នុងការកែទម្រង់ប្រព័ន្ធថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានក្នុងការកំណត់ហិរញ្ញប្បទានត្រៀមទុកជាមុន សម្រាប់ដោះស្រាយ និងគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- បង្ហាញនូវការជឿទុកចិត្ត ចំពោះបែបបទក្នុងការទទួល និងគ្រប់គ្រងហិរញ្ញវត្ថុ គាំទ្រសកម្មភាពបំរែបំរួលអាកាសធាតុ ដែលផ្តល់ពីប្រភពខាងក្រៅ ដែលប្រទេសនិមួយៗទទួលបាន ហើយស្របទៅនឹងគោលនយោបាយពាក់ព័ន្ធ ផ្សេងទៀតដូចជាគោលនយោបាយអភិវឌ្ឍន៍

ការលើកទឹកចិត្តដល់ដៃគូអភិវឌ្ឍន៍

- ប្រើប្រាស់ប្រព័ន្ធ និងនីតិវិធីដែលជឿទុកចិត្តបានរបស់ប្រទេសនិមួយៗ គឺជាជំរើសដំបូងសំរាប់ការផ្តល់មូលនិធិបំរែបំរួលអាកាសធាតុពីប្រភពខាងក្រៅ ក្នុងករណីមិនអាចប្រើបាន គឺគ្រាន់តែបង្កើតប្រព័ន្ធសុវត្ថិភាពបន្ថែម និងវិធានការមួយចំនួនជាមធ្យោបាយដែលនឹងអាចជួយពង្រឹងអោយកាន់តែប្រសើរជាងមុន ជៀសវាងការលុបចោលនូវប្រព័ន្ធរបស់រដ្ឋាភិបាល ។
- គាំទ្រនូវការខិតខំប្រឹងប្រែងដែលកំពុងអនុវត្តនិងការកំណែទំរង់សំរាប់អនាគតដើម្បីធ្វើអោយមានសុខដុមនីយកម្ម និងអាចប៉ាន់ស្មានទុកជាមុនបាន។
- ផ្តល់ការអភិវឌ្ឍន៍បច្ចេកទេសដើម្បីពង្រឹងសមត្ថភាពស្ថាប័ននិងការអភិវឌ្ឍន៍សមត្ថភាពជាតិទាំងមូលប្រកបដោយនិរន្តភាព។

ទីបី: ដើម្បីអនុវត្តក្របខ័ណ្ឌនៃការទទួលខុសត្រូវការរៀបចំរបាយការណ៍ចំណាយដែលទាក់ទងនឹងបំរែបំរួលអាកាសធាតុ និងផល ប៉ះពាល់

ការលើកទឹកចិត្តដល់ប្រទេសកំពុងអភិវឌ្ឍន៍ ៖

- រួមបញ្ចូលហិរញ្ញប្បទានបំរែបំរួលអាកាសធាតុទៅក្នុងប្រព័ន្ធការទទួលខុសត្រូវនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ធ្វើការដឹកនាំជាពិសេសក្នុងការផ្តល់គោលការណ៍លើការពិភាក្សាស្តីពីបរិមាណ និងគុណភាពរបស់មូលនិធិបំរែបំរួលអាកាសធាតុ
- ធានាថាប្រព័ន្ធនៃការទទួលខុសត្រូវមានសារៈសំខាន់សំរាប់ការផ្តល់ការ

ការលើកទឹកចិត្តដល់ដៃគូអភិវឌ្ឍន៍

- យន្តការគណនេយ្យភាពទ្វេទិស ដែលពាក់ព័ន្ធគ្នាទៅវិញទៅមកនៅតាមប្រទេសនិមួយៗនៃការបង្កើតលក្ខណៈវិនិច្ឆ័យ ដូចជាការប៉ាន់ស្មានគុណភាព និងតម្លាភាពរបស់មូលនិធិពីខាងក្រៅ ។
- ធានាអោយមានតម្លាភាព ដោយរួមបញ្ចូលទាំងការចូលរួមពីខាងក្រៅទៅក្នុងប្រព័ន្ធគណនេយ្យភាពតាមប្រទេសជាតិនិមួយៗ។
- ធានាថាក្របខ័ណ្ឌតាមដានត្រួតពិនិត្យអន្តរជាតិអាចជះឥទ្ធិពលទៅលើប្រព័ន្ធគណនេយ្យភាពរបស់ប្រទេសនីមួយៗ និងដំណើរការអនុវត្ត ការតាមដាន ត្រួតពិនិត្យទៅលើដំណើរការរបស់ប្រទេសនិមួយៗ តាមដែលអាចធ្វើទៅបាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាបជាសេចក្តីរាយការណ៍ និងមានមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**សក់_សេដ្ឋា**